**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត
## សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាសអបអរសាទរទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៣ ឆ្នាំ២០២១

*បងប្អូនជនរួមជាតិទាំងអស់ជាទីស្រឡាញ់រាប់អាន!*

ថ្ងៃនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជានិងខ្លួនខ្ញុំផ្ទាល់ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំមានសេចក្តីសោមនស្សរីករាយ សូមផ្ញើសារនេះជូនដល់បងប្អូនជនរួមជាតិទាំងអស់ ជាពិសេស សិល្បករ សិល្បការិនី សិប្បករ និងអ្នកជំនាញនានានៅក្នុងវិស័យសិល្បៈ ព្រមទាំងក្មួយៗជាយុវជន ចូលរួមអបអរសាទរ"**ទិវាវប្បធម៌ជាតិ៣មីនា លើកទី២៣ ឆ្នាំ២០២១**" ក្រោមប្រធានបទ "**យុវជនដើម្បីវប្បធម៌ជាតិ**" ។ ទិវាវប្បធម៌នេះត្រូវបានប្រារព្ធធ្វើឡើងនៅថ្ងៃទី៣មីនា ជារៀងរាល់ឆ្នាំ ប៉ុន្តែខ្ញុំក៏សូមការអធ្យាស្រ័យ ដោយសារឆ្នាំ២០២១នេះ យើងមិនអាចរៀបចំការជួបជុំដូចសព្វមួយដង ដោយសារការរីករាលដាលជាសកលនៃជំងឺកូវីដ១៩ ដែលកំពុងគំរាមកំហែងដល់សុខភាពសាធារណៈ សេចក្តីសុខ និងអាយុជីវិតរបស់ប្រជាជនកម្ពុជា ក៏ដូចជាប្រជាជននានាទូទាំងសកលលោក។

ឆ្នាំនេះ គឺជាឆ្នាំទី៤ដែលត្រូវរៀបចំពិធីជំនួបរវាងប្រមុខរាជរដ្ឋាភិបាលជាមួយសិល្បករ សិល្បការិនី សិប្បករ និងអ្នកមានអាជីពក្នុងវិស័យវប្បធម៌ប្រមាណ៤០០០នាក់ ដែលជាការជួបជុំដ៏ធំប្រចាំឆ្នាំ ក្នុងគោលបំណងរំលឹកនូវគុណូបការៈនៃបុព្វបុរសខ្មែរ ដែលបានបន្សល់ទុកនូវស្នាដៃអច្ឆរិយៈដ៏ធំមហិមាសម្រាប់ប្រជាជាតិខ្មែរ ក៏ដូចជាមនុស្សជាតិនានាលើសកលលោក និងដើម្បីពង្រឹងនូវសាមគ្គីភាព ភាតរភាព ការស្គាល់និងជួយគ្នាទៅវិញទៅមក រវាងអ្នកមានអាជីពគ្រប់ៗគ្នាក្នុងវិស័យសិល្បៈ ក្រោមម្លប់សុខសន្តិភាពនិងការអភិវឌ្ឍប្រកបដោយចីរភាពយូរអង្វែង ដែលជាផ្លែផ្កានៃនយោបាយ ឈ្នះ ឈ្នះ ជាង២០ឆ្នាំកន្លងមក។

*បងប្អូនជនរួមជាតិទាំងអស់ជាទីស្រឡាញ់រាប់អាន!*

រយៈពេលជិត១ឆ្នាំមកនេះ ការរីករាលដាលនៃវីរុសកូវីដ១៩ រួមទាំងការបំប្លែងខ្លួនជាវីរុសប្រភេទថ្មីផងនោះ បាននិងកំពុងរាតត្បាតជាបន្តបន្ទាប់និងជះឥទ្ធិពលអវិជ្ជមានមកលើសង្គមនិងសេដ្ឋកិច្ច នៅតាមបណ្តាប្រទេសនានាក្នុងពិភពលោក ក្នុងតំបន់ និងក្នុងប្រទេសកម្ពុជាយើង ដែលក្នុងនោះរួមមានទាំងវិស័យវប្បធម៌ផងដែរ។ ដោយសារការរីករាលដាលនៃជំងឺកូវីដ១៩ សារមន្ទីរ រោងភាពយន្ត និងរោងសម្ដែងសិល្បៈនៅទូទាំងប្រទេស បានតម្រូវឱ្យបិទទ្វារបណ្ដោះអាសន្នជាច្រើនលើក រីឯវិស័យឯកជនដែលធ្វើអាជីវកម្មនៅក្នុងផ្នែកសិល្បៈវប្បធម៌ រួមមានក្រុមហ៊ុន ក្រុមតន្ត្រី និងក្រុមសិល្បៈទាំងអាជីពនិងមហាជន ដែលពឹងផ្អែកលើភ្ញៀវទេសចរជាតិនិងអន្តរជាតិ ជាពិសេសពិធីដែលជាតម្រូវការផ្នែកសិល្បៈវប្បធម៌ដូចជាពិធីរៀបអាពាហ៍ពិពាហ៍របស់បងប្អូនប្រជាជនយើងក៏ត្រូវបានផ្អាក ឬរឹតត្បិតលក្ខខណ្ឌរៀបចំយ៉ាងយកចិត្តទុកដាក់បំផុតស្របទៅតាមការកំណត់របស់រាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់ការរីករាលដាលនៃការឆ្លងចូលទៅក្នុងសហគមន៍។ ជារួម វិបត្តិកូវីដ១៩ បានធ្វើឱ្យទីផ្សារការងារនិងចំណូលពីផ្នែកសិល្បៈវប្បធម៌ រងនូវផលប៉ះពាល់ធ្ងន់ធ្ងរ ទាំងផ្ទាល់និងប្រយោល។

ប៉ុន្តែទោះជាយ៉ាងនេះក្ដី អ្នកដែលមានអាជីពក្នុងវិស័យនេះបានខិតខំពុះពារជម្នះរាល់ការលំបាកនានា ជាបុគ្គលផ្ទាល់ក្ដី ជាការផ្ដុំគ្នាជាក្រុមក្ដី ផ្សព្វផ្សាយចែករំលែកការណែនាំនានាពីហានិភ័យនៃជំងឺកូវីដ១៩ ក៏ដូចជាបង្កើតនូវស្នាដៃផ្សេងៗក្នុងវិស័យវប្បធម៌ ផ្សព្វផ្សាយទៅក្នុងបណ្ដាញព័ត៌មាន ឬទៅកាន់មហាជន ដើម្បីរក្សានិងលើកតម្កើងសិល្បៈវប្បធម៌ខ្មែរពុំឱ្យមានការដាច់ដោចទាំងស្រុងនោះឡើយ ទោះជាវិស័យភាពយន្ត សិល្បៈ និងសកម្មភាពវប្បធម៌ផ្សេងទៀតក្ដី។ បន្ថែមពីលើនោះទៀត បងប្អូនយើងបានចូលរួមលះបង់នូវធនធានផ្ទាល់ខ្លួន ជាវិភាគទានជាមួយរាជរដ្ឋាភិបាល សម្រាប់ដោះស្រាយបញ្ហាគ្រោះទឹកជំនន់ ជួយជនរងគ្រោះក្នុងវិបត្តិកូវីដ១៩ និងការទិញវ៉ាក់សាំងទប់ស្កាត់នូវជំងឺនេះផងដែរ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសម្ដែងនូវអំណរគុណ និងកោតសរសើរដោយស្មោះអស់ពីចិត្ត ចំពោះសេចក្ដីក្លាហាន សេចក្ដីស្រឡាញ់ និងការការពារយ៉ាងប្តូរផ្តាច់របស់បងប្អូនយើងទាំងអស់ ចំពោះសិល្បៈនិងវប្បធម៌ជាតិ។

ដូចបងប្អូនជនរួមជាតិទាំងអស់បានជ្រាបរួចមកហើយថា ប្រវត្តិសាស្ត្របានបញ្ជាក់យ៉ាងច្បាស់អំពីសាវតារដ៏រុងរឿងគួរជាទីស្ញប់ស្ញែងរបស់ព្រះរាជាណាចក្រកម្ពុជា ដែលជាប្រទេសមួយមានមរតកវប្បធម៌យ៉ាងសម្បូណ៌បែប ទាំងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ក៏ដូចជានៅក្នុងពិភពលោកទាំងមូល។ វប្បធម៌ គឺមិនត្រឹមតែជាព្រលឹងនិងជាអត្តសញ្ញាណជាតិប៉ុណ្ណោះទេ តែក៏ជាវិស័យមួយដែលមានសក្ដានុពលនិងកំពុងវិវឌ្ឍខ្លួនទៅក្នុងដំណើរការធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិ ក៏ដូចជាការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាប័ន្ននៅកម្ពុជាផងដែរ។

ទោះបីការរីករាលដាលនៃជំងឺឆ្លងកូវីដ១៩នៅតែជាបញ្ហាប្រឈមចម្បងយ៉ាងណាក្ដី ក៏រាជរដ្ឋាភិបាលកម្ពុជានៅតែបង្ហាញឆន្ទៈដ៏រឹងមាំ ក្នុងការបន្តរៀបចំតាមបែបបទនៃការរស់នៅបែបថ្មីនៃ **"ទិវាវប្បធម៌ជាតិ"** ដែលជាព្រឹត្តិការណ៍វប្បធម៌ប្រចាំឆ្នាំដ៏ធំ ហើយដែលត្រូវបានរៀបចំឡើងចំនួន២២លើករួចមកហើយចាប់តាំងពីឆ្នាំ១៩៩៩មក។ ស្របតាមការរស់នៅក្នុងគន្លងបែបថ្មី ការជួបជុំមនុស្សដោយផ្ទាល់ក្នុងចំនួនច្រើន ត្រូវជំនួសមកវិញនូវការរៀបចំកម្មវិធីសិល្បៈអបអរសាទរផ្សេងៗតាមប្រព័ន្ធអនឡាញ ដែលមិនបង្កហានិភ័យដល់សុខុមាលភាពរបស់ប្រជាជន។ សម្រាប់ឆ្នាំ២០២១នេះ ប្រធានបទ **"យុវជនដើម្បីវប្បធម៌ជាតិ"** ក្នុង **"ទិវាវប្បធម៌ជាតិ៣មីនា លើកទី២៣"** នៅតែមានសារៈសំខាន់និងស្របតាមបរិបទប្រជាសាស្ត្ររបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន និងបានបង្ហាញឱ្យឃើញថា ប្រជាជនវ័យកណ្ដាលដែលមានអាយុចាប់ពី១៥ ដល់៥៩ឆ្នាំ គឺមានការកើនឡើងរហូតដល់៦១,៧% ដែលក្នុងនោះ ក្រុមយុវជនមានអាយុចាប់ពី១៥ ដល់៣០ឆ្នាំ ជាផ្នែកមួយដ៏ធំផង។ កម្លាំងយុវជនគឺជាសក្ដានុពលធនធានមនុស្សដ៏សំខាន់មិនអាចខ្វះបាន នៅក្នុងការរួមចំណែកអភិរក្សនិងអភិវឌ្ឍវប្បធម៌ជាតិ ហើយក៏ជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍសង្គមជាតិផងដែរ។ ស្ថិតក្នុងបរិបទនៃការរីកចម្រើនជាសកលផ្នែកឌីជីថលនៅក្នុងសតវត្សរ៍ទី២១នេះ យុវជនកម្ពុជាមិនត្រឹមតែត្រូវមានការអប់រំ ការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈនិងចំណេះដឹងផ្នែកបច្ចេកវិទ្យាប្រកបដោយគុណភាពនិងសមធម៌ប៉ុណ្ណោះ តែក៏ត្រូវទទួលបានការចូលរួមយ៉ាងពេញលេញក្នុងសកម្មភាពសិល្បៈវប្បធម៌ ទាំងក្នុងទិដ្ឋភាពសង្គមនិងទិដ្ឋភាពសេដ្ឋកិច្ច។ សម្រាប់ទិដ្ឋភាពសង្គម យុវជនកម្ពុជាត្រូវទទួលបាននូវការលើកទឹកចិត្តនិងការបណ្ដុះស្មារតីស្នេហាជាតិ ស្នេហាប្រជាជន និងស្នេហាវប្បធម៌ជាតិ ដោយត្រូវរួមចំណែកយ៉ាងសកម្មក្នុងការអភិរក្ស ការផ្សព្វផ្សាយ និងការលើកស្ទួយតម្លៃវប្បធម៌និងសិល្បៈជាតិ ចៀសវាងនូវការភ្លើតភ្លើន ភ្លេចខ្លួនបំផ្លាញវប្បធម៌ជាតិខ្លួនឯងផ្ទាល់។ ដោយឡែក សម្រាប់ទិដ្ឋភាពសេដ្ឋកិច្ចវិញ យុវជនត្រូវចូលរួមឱ្យកាន់តែសកម្មថែមទៀតនៅក្នុងសកម្មភាពគាំទ្រការផ្ដួចផ្ដើមនិងគំនិតច្នៃប្រឌិតបង្កើតថ្មី ដោយឈរលើមូលដ្ឋានរក្សាការពារអត្តសញ្ញាណជាតិនិងស្មារតីសហគ្រិនភាពឱ្យបានកាន់តែផុសផុលឡើងថែមទៀត ដើម្បីពង្រឹងនិងពង្រីកសេដ្ឋកិច្ចវប្បធម៌ឱ្យកាន់តែរីកចម្រើន ដោយយកចិត្តទុកដាក់រក្សាលំនឹងនៃការអភិវឌ្ឍផ្នែកសិល្បៈវប្បធម៌ទន្ទឹមគ្នាជាមួយការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។

*បងប្អូនជនរួមជាតិទាំងអស់ជាទីស្រឡាញ់!*

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែង ដោយឈរលើស្មារតីសហការនិងទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បី

សម្រេចឱ្យបាននូវបេសកកម្មក្នុងបុព្វហេតុអភិរក្សនិងអភិវឌ្ឍវប្បធម៌ជាតិ។ ក្រៅពីការចូលរួមក្នុងកម្មវិធីកំណែទម្រង់សំខាន់ៗទាំង៣របស់រាជរដ្ឋាភិបាល ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបាននិងកំពុងរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្ត "យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤" ព្រមទាំង "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០២៣" ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦នៃរដ្ឋសភា។ ទោះបីស្ថិតក្នុងស្ថានភាពដ៏អាក្រក់នៃវិបត្តិកូវីដ១៩ក៏ដោយ ក៏ក្រសួងវប្បធម៌និងវិចិត្រសិល្បៈនៅតែបង្ហាញឱ្យឃើញនូវកិច្ចខិតខំប្រឹងប្រែងនិងភាពជោគជ័យជាបន្តបន្ទាប់។

ក្នុងកិច្ចគាំពារនិងអភិរក្សបេតិកភណ្ឌវប្បធម៌អរូបីជាតិ ទូលព្រះបង្គំជាខ្ញុំ សូមសម្តែងនូវគារវកិច្ចនិងការគោរពដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ដែលបានបរិច្ចាគទ្រព្យផ្ទាល់របស់ព្រះអង្គ ដល់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីឆ្លាក់ចម្លងស្បែកធំមួយឈុតថ្មីចំនួន៩០ផ្ទាំង ក្នុងរឿង"រាមកេរ្តិ៍" ព្រមទាំងរៀបចំចងក្រងជាអត្ថបទ និងវីដេអូឯកសារសម្រាប់ការសិក្សាស្រាវជ្រាវរបស់កូនចៅជំនាន់ក្រោយ។ ព្រះរាជបូបត្ថម្ភដ៏ថ្លៃថ្លានេះគឺជាការយកព្រះរាជហឫទ័យទុកដាក់ខ្ពស់ចំពោះការអភិរក្សសម្បត្តិវប្បធម៌ជាតិ ជាពិសេសសម្រាប់ល្ខោនស្រមោលស្បែកធំដែលជាអត្តសញ្ញាណជាតិនិងជាបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ។

ជាមួយគ្នានេះ ខ្ញុំក៏សូមសម្តែងនូវមោទនភាពសប្បាយរីករាយ និងចូលរួមអបអរសាទរជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រួមទាំងស្ថាប័នពាក់ព័ន្ធនានា ចំពោះភាពជោគជ័យនៃកិច្ចចរចារយៈពេលជាង ៣ឆ្នាំកន្លងមក ក្នុងការធ្វើមាតុភូមិនិវត្តន៍វត្ថុបុរាណខ្មែរចំនួនជាង១០០រូបពីបរទេសមកវិញ ដែលអាចចាត់ទុកថា នេះជាការវិលត្រឡប់នៃវត្ថុបុរាណខ្មែរដ៏ច្រើនបំផុតមិនធ្លាប់មានពីពេលមុនមក ហើយដែលក្នុងនោះសុខសន្តិភាពនិងស្ថេរភាពនយោបាយ គឺជាបុរេលក្ខខណ្ឌដ៏សំខាន់បំផុតចំពោះបេសកកម្មយាងនិងអញ្ជើញព្រលឹងរបស់បុព្វបុរសខ្មែរត្រឡប់មកមាតុភូមិវិញជាមង្គលរបស់ជាតិ និងឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងបុព្វហេតុដ៏ឧត្តុង្គឧត្តមដើម្បីវប្បធម៌ជាតិ។

បន្ថែមពីលើនោះ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការវិនិយោគរៀបចំកែលម្អហេដ្ឋារចនាសម្ព័ន្ធនិងសោភ័ណភាពនៃទីក្រុងសៀមរាប-អង្គរ ដែលជាដួងព្រលឹងជាតិនិងជាបេតិកភណ្ឌវប្បធម៌ពិភពលោក ដូចដែលត្រូវបានប្រកាសជា"**ទីក្រុងវប្បធម៌អាស៊ាន**" សម្រាប់ឆ្នាំ២០២១-២០២២ នៅក្នុងកិច្ចប្រជុំលើកទី៩ របស់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកវប្បធម៌និងសិល្បៈដែលប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះនៅឆ្នាំ២០២០។ តាមរយៈការអភិរក្សជួសជុលសំណង់និងវត្ថុបុរាណជាច្រើននិងការកែប្រែមុខមាត់ថ្មីនៃរមណីយដ្ឋានអង្គរគឺជាការជួយរក្សានូវតឹកតាងប្រវត្តិសាស្ត្រនិងកិត្យានុភាពជាតិ ហើយការថែរក្សាការពារនេះអាចទទួលបានជោគជ័យនិងមាននិរន្តរភាពទៅបាន គឺតម្រូវឱ្យមានការចូលរួមគាំទ្រនិងជ្រោមជ្រែងពីគ្រប់មជ្ឈដ្ឋានទាំងអស់ ជាពិសេសអាជ្ញាធរដែនដីនិងប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់បេតិកភណ្ឌ។

ខ្ញុំក៏សូមគាំទ្រដោយពេញចិត្ត ចំពោះគំនិតផ្តួចផ្តើមរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្នុងការរៀបចំចងក្រងឯកសារសិក្សាស្រាវជ្រាវកម្រិតថ្នាក់ជាតិលើកដំបូងស្តីពីរបាំព្រះរាជទ្រព្យ ឬរបាំក្បាច់បុរាណ ដែលជាបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ រួមទាំងការសិក្សាស្រាវជ្រាវនិងចងក្រងក្រាំងចម្រៀង សម្រាប់ច្រៀងអមនិងកំដររបាំព្រះរាជទ្រព្យឬរបាំក្បាច់បុរាណ ដែលជារបាំមូលដ្ឋានគ្រឹះតាំងពីបុរាណ ហើយអាចច្នៃប្រឌិតបង្កើតទៅជាចម្រៀងថ្មីៗសម្រាប់ច្រៀងអម ឬកំដរក្នុងស្នាដៃរបាំថ្មីៗផ្សេងទៀត។ ឯកសារសិក្សាស្រាវជ្រាវនេះ នឹងក្លាយទៅជាឯកសារគោលដ៏មានសារៈសំខាន់ថ្មីមួយទៀត ដើម្បីទុកជាក្បួនខ្នាតសម្រាប់ការហាត់រៀនរបាំរបស់ក្មេងៗជំនាន់ក្រោយ។

ទន្ទឹមគ្នានេះដែរ ការដំឡើងទម្រង់សិល្បៈតាមរូបភាពអភិវឌ្ឍថ្មីមួយចំនួនដើម្បីផ្សាយតាមប្រព័ន្ធអនឡាញ កំពុងទទួលបានការស្វាគមន៍និងការចូលរួមពីមហាជនគ្រប់ស្រទាប់ គ្រប់វ័យ ទាំងក្នុងនិងក្រៅប្រទេសយ៉ាងច្រើនកុះករហួសពីការស្មាន ហើយដែលនេះជាសកម្មភាពថ្មីក្នុងការរស់នៅតាមបរិបទថ្មី និងជាបទពិសោធន៍ជោគជ័យមួយដែលត្រូវតែបន្តលើកទឹកចិត្ត។

*បងប្អូនជនរួមជាតិទាំងអស់ជាទីស្រឡាញ់!*

ជាទីបញ្ចប់ ខ្ញុំសូមឧទ្ទិសនូវរាល់សមិទ្ធផលវប្បធម៌ដែលសម្រេចបានទាំងអស់ដល់គុណូបការៈរបស់បុព្វបុរសខ្មែរគ្រប់ជំនាន់ ព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់កាលសម័យ ព្រលឹងអ្នកវប្បធម៌ទាំងអស់ដែលបានពលីទាំងកម្លាំងកាយ កម្លាំងចិត្ត និងកម្លាំងបញ្ញា បន្សល់ទុកនូវមរតកមហាសាលផ្នែកវប្បធម៌ដ៏សម្បូណ៌បែបនិងមានតម្លៃមិនអាចកាត់ថ្លៃបាន សម្រាប់កូនចៅជំនាន់ក្រោយ។ ខ្ញុំសូមអំពាវនាវ ឱ្យកូនខ្មែរគ្រប់ៗរូប ជាពិសេសយុវជនត្រូវខិតខំថែរក្សានិងការពារនូវអ្វីៗទាំងអស់ដែលជាព្រលឹងជាតិនិងអត្តសញ្ញាណជាតិ សម្រាប់ជាមរតកយូរអង្វែងតទៅដល់កូនខ្មែរជំនាន់ក្រោយ ហើយក៏សូមចូលរួមទាំងអស់គ្នាប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងកូវីដ១៩ ដើម្បីរក្សាការពារកម្ពុជាព្រះរាជាណាចក្រវប្បធម៌និងអច្ឆរិយៈ ឱ្យរុងរឿងជានិរន្តរតរៀងទៅ។

ខ្ញុំសូមជូនពរបងប្អូនជនរួមជាតិទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមឱ្យមនសិការស្នេហាជាតិនិងស្មារតីស្រឡាញ់សិល្បៈវប្បធម៌ជាតិ រីកដុះដាលក្នុងស្មារតីនិងសកម្មភាពរបស់ជនជាតិខ្មែរគ្រប់ៗរូប ជាពិសេសក្នុងចំណោមយុវជនខ្មែរ ដើម្បីបន្តវេនទទួលខុសត្រូវថែរក្សាការពារសម្បត្តិវប្បធម៌ជាតិទាំងអស់ ឱ្យបានគង់វង្សជានិច្ចនិរន្តរ៍។

ថ្ងៃច័ន្ទ ៣រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០២១

**ហ៊ុន សែន**